Peace Corps
CAMBODIA




# របាយការណ៍ប្រចាំឆ្នាំ

# ២០២៤

សន្តិភាព និងមិត្តភាពពិភពលោក

**ទីភ្នាក់ងារ ភីស ខ័រ កម្ពុជា**

ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦

រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ២៤៥៣

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២២២ ៩០១

ទូរសារលេខ៖ (៨៥៥) ២៣ ២២២ ៩០៣

អ៊ីម៉ែល៖ KH-WebInfo@peacecorps.gov

**PC Facebook:**

**PC Instagram:**

**PC Website:**

**ខែធ្នូ ឆ្នាំ ២០២៤**

ទីភ្នាក់ងារ ភីស ខ័រ គឺជាស្ថាប័នដែលមិនប្រកាន់និន្នាការនយោបាយ និងសាសនា របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលធ្វើការដើម្បីលើកកម្ពស់សន្តិភាព និងមិត្តភាពរវាងប្រជាជននៃប្រទេស និងវប្បធម៌ផ្សេងគ្នា។អស់រយៈពេលជាងប្រាំមួយទស្សវត្សរ៍កន្លងទៅនេះ ទីភ្នាក់ងារ ភីស ខ័រ បានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេស ចំនួន ១៤១ តាមរយៈការអនុវត្តគម្រោង កសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន។

# មាតិកានុក្រម


០២ សារពីនាយិកាប្រចាំប្រទេស

០៣ ការបង្រៀនភាសាអង់គ្លេស និង ការបណ្តុះបណ្តាលគ្រូបង្រៀន

០៤ សមិទ្ធផលសំរេចបានពីគម្រោង អប់រំក្នុងឆ្នាំ ២០២៤

០៦ ដំណើររឿងជោគជ័យរបស់គម្រោងអប់រំ

០៨ កម្មវិធីគម្រោងអភិវឌ្ឍន៍ខ្នាតតូច និងសមិទ្ធផល

០៩ ដំណើររឿងជោគជ័យនៃគម្រោង អភិវឌ្ឍន៍ខ្នាតតូច

១១ ការបណ្តុះបណ្តាលបឋម

១៦ វគ្គបណ្តុះបណ្តាលនានារបស់ ភីស ខ័រ



# សារពី
# នាយិកាប្រចាំប្រទេស

បេសកកម្មរបស់ទីភ្នាក់ងារភីស ខ័រ គឺ *“សន្តិភាព និង មិត្តភាពពិភពលោក។”* យើងបំពេញបេសកកម្មរបស់យើងតាមរយៈការបម្រើសេវាកម្មជាអ្នកស្ម័គ្រចិត្ត។ អ្នកស្ម័គ្រចិត្តរបស់យើងរស់នៅនិងធ្វើការរយៈពេលពីរឆ្នាំនៅក្នុងសហគមន៍ជាមួយគ្រួសារខ្មែរ ដើម្បីជ្រួតជ្រាប និងសម្របខ្លួនតាម វប្បធម៌ក្នុងមូលដ្ឋាន។ ប្រការនេះនឹង ជួយឱ្យពួកគេបង្កើតបាននូវទំនាក់ទំនងប្រកបដោយអត្ថន័យ មើលឃើញពីទស្សនៈថ្មីមួយ និងរួមចំណែកដល់ការអភិវឌ្ឍកម្ពុជា និងប្រើប្រាស់ជំនាញបច្ចេកទេសរបស់ពួកគេយ៉ាងសមស្រប នៅក្នុងបរិស្ថាន និង វប្បធម៌ថ្មី។

អ្នកស្ម័គ្រចិត្ត បាននឹងកំពុងធ្វើការជាមួយគ្រូបង្រៀននៅទូទាំងប្រទេស ដើម្បីរួមចំណែកដល់ការអភិវឌ្ឍការអប់រំភាសាអង់គ្លេស នៅកម្ពុជា។ លើសពីនេះ ពួកគេបានធ្វើការជាមួយសហការី និងមិត្តភក្តិក្នុងស្រុក លើគម្រោងអភិវឌ្ឍន៍សហគមន៍ផ្សេងៗ ជាច្រើន ដូចជាការអភិវឌ្ឍសួនដំណាំសាលា ដែលជួយកែលម្អអាហារូបត្ថម្ភរបស់កុមារនិងគ្រួសារ ឬការបង្កើតបណ្ណាល័យមួយ ដែលជាធនធានមួយសម្រាប់សាលារៀន និង សហគមន៍។

មិនថាពួកគេធ្វើការជាគ្រូបង្រៀន ឬជាមួយសហគមន៍លើគម្រោងអភិវឌ្ឍន៍មួយក្តី ក៏គោលដៅគឺជាការកសាងសមត្ថភាពក្នុងមូលដ្ឋានដែរ។ តាមរយៈធ្វើការជាមួយអ្នកស្ម័គ្រចិត្ត សមាជិកសហគមន៍ អាចរៀនសូត្រដើម្បីកំណត់សមត្ថភាពជាអ្នកដឹកនាំរៀនរកធនធាននិងរៀនអនុវត្តការធ្វើការរួមគ្នាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍សហគមន៍ដែលបំពេញតាមសេចក្តីត្រូវការនិងកាលានុវត្តភាពនានាដែលបានកំណត់ជាអាទិភាពដោយសហគមន៍។ តួនាទីរបស់អ្នកស្ម័គ្រចិត្ត គឺចូលរួមជាសមាជិកថ្មីមួយរូបនៃសហគមន៍ និងជួយសម្រួលកិច្ចដំណើរការនេះ។

នៅពេលធ្វើការ និងរស់នៅក្នុងសហគមន៍ អ្នកស្ម័គ្រចិត្តរបស់យើងក៏ចែករំលែកផងដែរនូវវប្បធម៌និងទំនៀមទម្លាប់ផ្សេងៗរបស់សហរដ្ឋអាមេរិក ដើម្បីជួយឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរ។ អ្នកស្ម័គ្រចិត្តអាចចែករំលែកអំពីវប្បធម៌ និង ប្រពៃណីដ៏សម្បូណ៌បែបនៃប្រទេសកម្ពុជាដែលពួកគេបានរៀន ទៅកាន់គ្រួសារ និងមិត្តភក្តិនៅសហរដ្ឋអាមេរិក។ មិត្តភាពដែលបានបង្កើតឡើងក្នុងអំឡុងពេលពីរឆ្នាំនៃការរស់នៅនិងធ្វើការនៅក្នុងសហគមន៍នៅកម្ពុជាតាមរយៈការចែករំលែកគ្នានេះ អាចស្ថិតស្ថេរពេញមួយជីវិត និងជាកម្លាំងជំរុញនៅពីក្រោយបេសកកម្មយើងក្នុងការកសាង សន្តិភាព និង មិត្តភាពពិភពលោក។

យើងបន្តថ្លែងអំណរគុណចំពោះភាគីម្ចាស់ផ្ទះ ពោលគឺរាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើឱ្យកិច្ចសហការនេះអាចដំណើរការបាន តាមរយៈការអញ្ជើញទីភ្នាក់ងារភីស ខ័រ ឱ្យមកធ្វើការក្នុងភាពជាដៃគូ ដើម្បីបំពេញគម្រោងអភិវឌ្ឍន៍ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ។ របាយការណ៍ប្រចាំឆ្នាំនេះ ក៏ចូលរួមអបអរសាទរខួប ១៧ឆ្នាំនៃកិច្ចសហការជាមួយមន្ត្រីសមភាគីដៃគូអ្នកមានវិជ្ជាជីវៈកម្ពុជានៅក្នុងគ្រឹះស្ថានអប់រំនានា និងការកសាងទំនាក់ទំនងជាមួយគ្រួសារខ្មែរក្នុងកម្រិតសហគមន៍ និង ជាលក្ខណៈបុគ្គល។

ទិន្នន័យ និងដំណើររឿងដែលចែករំលែកនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៤នេះ តំណាងឱ្យស្មារតីនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រវាងមនុស្ស និងមនុស្សរបស់ទីភ្នាក់ងារភីស ខ័រ ដែលអាចកើតឡើងបានតែនៅពេលដែលយើងរៀនសូត្រ និងរីកចម្រើនរួមគ្នាតែប៉ុណ្ណោះ។ យើងមានមោទកនភាពក្នុងការចែករំលែកសមិទ្ធផលសហការរបស់អ្នកស្ម័គ្រចិត្តរបស់យើង និងសមភាគីកម្ពុជានៅក្នុងឆ្នាំ ២០២៤ តាមរយៈរបាយការណ៍ប្រចាំឆ្នាំនេះ។

# ការបង្រៀនភាសាអង់គ្លេស និងការបណ្តុះបណ្តាលគ្រូបង្រៀន

គម្រោងបង្រៀនភាសាអង់គ្លេស និងបណ្តុះបណ្តាលគ្រូ (ETTT) បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅកម្ពុជាតាំងពីឆ្នាំ ២០០៧។ គម្រោងនេះបានធ្វើការដើម្បីអភិវឌ្ឍភាសាអង់គ្លេសរបស់សិស្ស គ្រូ និងសមាជិកសហគមន៍កម្ពុជា ដើម្បីជួយពួកគេឱ្យមានលទ្ធភាពទទួលបានឱកាសផ្ទាល់ខ្លួន ឱកាសវិជ្ជាជីវៈ និងឱកាសសិក្សា។

អ្នកស្ម័គ្រចិត្តបង្រៀននៅតាម សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និង មជ្ឈមណ្ឌលគរុកោសល្យ។ អ្នកស្ម័គ្រចិត្តសហការបង្រៀនជាមួយគ្រូជាជនជាតិខ្មែរ តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តបែបនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងសមត្ថភាពភាសារបស់គ្រូបង្រៀនកម្ពុជា និងកសាងជំនាញ បច្ចេកទេសគ្រប់គ្រងថ្នាក់រៀនរបស់ពួកគេទៀតផង។ តាមរយៈការបង្រៀនជាមួយគ្រូជនជាតិខ្មែរ អ្នកស្ម័គ្រចិត្តចែករំលែកការអនុវត្តការបង្រៀនប្រកបដោយភាពច្នៃប្រឌិត ជួយរៀបចំកិច្ចតែងការបង្រៀន និងបង្រៀនមេរៀន ជួយកសាងជំនាញភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង និងណែនាំបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។អ្នកស្ម័គ្រចិត្តក៏បង្កើត និងលើកកម្ពស់ផងដែរនូវធនធានបង្រៀននិងរៀនសម្រាប់ថ្នាក់រៀន រួមមានល្បែងសិក្សា និងណែនាំអំពីបច្ចេកវិទ្យាថ្មីៗផងដែរ។

ចាប់តាំងពីគម្រោងនេះបានចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០០៧រហូតមកដល់ឆ្នាំ២០២៤ពួកយើងទទួលបានអ្នកស្ម័គ្រចិត្តចំនួន ៧៥១នាក់បានបម្រើការងារនៅកម្ពុជា។ ដែលក្នុងនោះមានអ្នកស្ម័គ្រចិត្តចំនួន ២១៣នាក់បានបម្រើការលើគម្រោងអប់រំសុខភាពក្នុងសហគមន៍ និងអ្នកស្ម័គ្រចិត្តចំនួន ៥៣៨នាក់បម្រើការលើគម្រោងអប់រំភាសាអង់គ្លេសនៅតាមសាលារៀនក្នុងសហគមន៍។

## គោលដៅគម្រោង

សិស្សានុសិស្សកម្ពុជាទទួលបានជំនាញទំនាក់ទំនងជាភាសាអង់គ្លេស និងបំណិនជីវិតដែលចាំបាច់ដើម្បីមានលទ្ធភាពទទួលបានឱកាសសិក្សានិងឱកាសវិជ្ជាជីវៈ។

## គោលបំណងនៃគម្រោង

### ១. គ្រូបង្រៀន គ្រូឧទ្ទេស និងគរុនិស្សិត

បង្កើនសមត្ថភាពគ្រូបង្រៀន គ្រូឧទ្ទេស និងគរុនិស្សិតដើម្បីប្រើជំនាញបង្រៀនភាសាអង់គ្លេសទូទៅឱ្យកាន់តែមានប្រសិទ្ធភាព។

បង្កើនជំនាញភាសាអង់គ្លេសរបស់គ្រូភាសាអង់គ្លេស គ្រូឧទ្ទេស និងគរុនិស្សិត។ បង្កើនសមត្ថភាពគ្រូបង្រៀន គ្រូឧទ្ទេស និងគរុនិស្សិតអោយមានតុល្យភាពនៃការចូលរួមរវាងស្ត្រី និងបុរសនៅក្នុងថ្នាក់រៀន។

### ២. សិស្ស

បង្កើនសមិទ្ធផលរបស់សិស្សភាសាអង់គ្លេស។

បង្កើនបំណិនជីវិតរបស់សិស្ស។

### ៣. បរិយាកាសសិក្សា

កែលម្អបរិយាកាសសិក្សាសាលាតាមរយៈការកែលម្អសាលារៀន ការបង្កើនការចូលរួមរបស់សហគមន៍ និងការអភិវឌ្ឍធនធានសិក្សា។

# សមិទ្ធផលគម្រោងអប់រំក្នុងឆ្នាំ ២០២៤

ចំនួនខេត្ត
១៥

ចំនួនអ្នកស្ម័គ្រចិត្តបច្ចុប្បន្ន: ៦០ នាក់

បុរស ៣១ នាក់

ស្រី ៣១ នាក់

**បង្កើន**សមត្ថភាព គ្រូបង្រៀនក្នុងការប្រើប្រាស់ភាសាអង់គ្លេស និងជំនាញបង្រៀនទូទៅ

**២៤០**
ចំនួនគ្រូដែលចូលរួមក្នុងការធ្វើផែនការ និងបង្រៀនភាសាអង់គ្លេសរួមគ្នា

**បង្កើន**សមិទ្ធផលរបស់សិស្ស ក្នុងជំនាញភាសាអង់គ្លេស និងបំណិនជីវិត

**៥៧៨**
ចំនួនថ្នាក់រៀនដែល អ្នកស្ម័គ្រចិត្តបង្រៀន

**បង្កើន**លទ្ធភាពរបស់សមាជិកសហគមន៍ ដើម្បីគាំទ្រដល់លទ្ធភាពរៀនរបស់សិស្ស តាមរយៈការកែលម្អបរិយាកាសសិក្សារបស់សាលា

ចំនួនសមាជិកសហគមន៍ដែលចូលរួម ក្នុងគម្រោងកែលម្អបរិក្ខារសាលា

**១.២០៧**

ប្រធានក្រុមអ្នកស្ម័គ្រចិត្តភីស ខ័រ (PCVL) ៣ នាក់

៣៣ វិទ្យាល័យ
២០ សាលាបឋមសិក្សា

១ សាលាគរុកោសល្យខេត្ត

៣ អនុវិទ្យាល័យ

**៩៦%**
ភាគរយនៃគ្រូបង្រៀនដែលបង្ហាញចំនួនអប្បបរមានៃការអនុវត្តការបង្រៀនដែលត្រូវបានទទួលស្គាល់លើជំនាញបង្រៀនទូទៅ និងជំនាញបង្រៀនភាសាអង់គ្លេស

**២៦,៧៨១**
(ស្រី:១៤.៥៣២)
ចំនួនសិស្សដែលត្រូវបានបង្រៀនភាសាអង់គ្លេសនៅក្នុងសាលា

**៧៣៧**
ចំនួនសិស្សចូលរួមក្លឹបសិក្សាភាសាអង់គ្លេសក្រៅកម្មវិធីសិក្សា វគ្គបង្ហាត់បង្ហាញ និង/ឬជំរុំ

**៧៧%**
ភាគរយនៃសិស្សដែលបានបង្ហាញសមិទ្ធផលក្នុងវគ្គសិក្សាភាសាអង់គ្លេស

**៨៤%**
ភាគរយនៃសមាជិកសហគមន៍ដែលរាយការណ៍ថាសកម្មភាពចូលរួមការងារសាលាដែលរៀបចំដោយអ្នកស្ម័គ្រចិត្តបានបង្កើនសមត្ថភាពរបស់ពួកគេក្នុងការគាំទ្រលទ្ធភាពទទួលបានការសិក្សារបស់សិស្ស

Peace Corps CAMBODIA

# ដំណើររឿងជោគជ័យរបស់គម្រោងអប់រំ

## ការលេងល្បែងសិក្សាក្នុងពេលសម្រាកនៅសាលា ពីអ្នកស្ម័គ្រចិត្ត



**K15 PCV Kyle Fraser-Mines**

ក្មេងៗ នៅសាលារបស់ខ្ញុំសប្បាយចិត្ត ពេលដល់ម៉ោងរៀនអង់គ្លេសប៉ុន្តែពេលខ្លះ ខ្ញុំគិតថាពួកគេគ្រាន់តែ រំភើបក្នុងការលេងល្បែងសិក្សាតែប៉ុណ្ណោះ។ ជារៀងរាល់ថ្ងៃ យើងបញ្ចប់ថ្នាក់រៀន ជាមួយល្បែងសិក្សាខ្លីៗ ដើម្បីពិនិត្យ មើលវាក្យសព្ទដែលបានរៀន ក្នុងមេរៀនថ្ងៃនេះ ហើយល្បែងសិក្សាពិត ជាជំរុញសិស្សឱ្យខិតខំរៀនពាក្យថ្មីមែន។ ដោយសារពួកគេដឹងថា ពួកគេនឹងត្រូវការ វាក្យសព្ទទាំងនោះនៅពេលលេងល្បែង សិក្សាពួកគេព្យាយាមទន្ទេញវាក្យសព្ទទាំង នោះឱ្យចាំ នៅពេលខ្ញុំកំពុងបង្រៀន។ ប៉ុន្តែ ពួកគេហាក់បីដូចជាលេងល្បែងសិក្សាមិនទាន់បានគ្រប់គ្រាន់នៅក្នុងថ្នាក់រៀន ដូច្នេះ សិស្សានុសិស្សជាច្រើន បាននាំខ្ញុំលេងល្បែងសិក្សាជាមួយពួកគេអំឡុងពេលសម្រាក ១៥នាទីក្នុងថ្ងៃរៀនធម្មតា។ សិស្សថ្នាក់ទី៤ របស់ខ្ញុំពិតជាចូលចិត្តលេងល្បែងភ្លើងក្រហម បៃតង ប៉ុន្តែ នៅកម្ពុជា គេហៅល្បែងនេះថា កូកូម៉ា។ ពេលខ្ញុំឃើញគេលេងល្បែង កូកូម៉ា លើកដំបូង ខ្ញុំមានក្តីបារម្ភតិចតួចព្រោះឃើញគេច្រៀងចម្រៀងបទភ្លើងក្រហម បៃតង ពីល្បែង Squid Games ហើយនោះជាឯកសារយោងតែមួយគត់របស់ខ្ញុំសម្រាប់បទចម្រៀងនោះ។ ខ្ញុំបានដឹងយ៉ាងឆាប់រហ័ស ថាពួកគេមិនបានចម្លងល្បែង Squid Games ទេ។ ប៉ុន្តែ នោះគ្រាន់តែជារបៀបដែលពួកគេបានលេងល្បែង ភ្លើងក្រហម បៃតងនៅទីនេះអស់រយៈពេលជាយូរមកហើយ។ ដូច្នេះ ល្បែង Squid Games ពិតជាចម្លងពីពួកគេវិញទេ! សិស្សថ្នាក់ទី៥ របស់ខ្ញុំចូលចិត្តឱ្យខ្ញុំលេងបាល់ទាត់ជាមួយពួកគេពេលឈប់សម្រាក។ពួកគេប្រាប់ខ្ញុំថាខ្ញុំពិតជាពូកែលេងបាល់ទាត់ប៉ុន្តែ ខ្ញុំគិតថាព្រោះដោយសារខ្ញុំមានកម្ពស់ខ្ពស់ជាង និងមានវ័យច្រើនជាងពួកគេដូច្នេះហើយទើបខ្ញុំបានកែលម្អជំនាញរបស់ខ្ញុំ បន្ថិចថែមទៀត។ ខ្ញុំពិតជាលេងបាល់ទាត់មិនអន់ទេ ប៉ុន្តែ ពួកគេវាយតម្លៃសមត្ថភាពរបស់ខ្ញុំលើស។ មានក្មេងប្រុសម្នាក់ ក្នុងថ្នាក់ទី៥ខ របស់ខ្ញុំ ពិតជាពូកែណាស់! គាត់ដើរបណ្តើរបាល់លេងគេចអ្នកលេងគ្រប់គ្នា និងមានបច្ចេកទេសលេងគួរឱ្យ ចាប់អារម្មណ៍យ៉ាងខ្លាំង។ ថ្វីត្បិតតែខ្ញុំបែកញើស និងហត់ក្នុងការលេងល្បែងជាមួយសិស្សពេលសម្រាកក៏ដោយក៏វាជា ពេលវេលាដែលខ្ញុំចូលចិត្តបំផុតក្នុងមួយថ្ងៃៗ ព្រោះពួកគេត្រឹមតែជាក្មេងរឡិរឡក់ និងសប្បាយរីករាយ! ពួកគេមិនខ្វល់ថា តើពួកគេរៀនពូកែនៅក្នុងថ្នាក់ឬយ៉ាងណាទេ គឺឱ្យតែពួកគេបានលេងជាមួយមិត្តភក្តិរបស់ពួកគេ!

## ការសហការគូរផែនទីពិភពលោកជាមួយគ្រូនិងសិស្សានុសិស្ស ពីអ្នកស្ម័គ្រចិត្ត



**K15 PCV Talia Desanto**

តាមរយៈការបង្កើតផ្ទាំងគំនូរផែនទី ពិភពលោកលើជញ្ជាំងមួយនៅក្នុងបណ្ណាល័យ សិស្សានុសិស្ស និងគ្រូបង្រៀនបានរួមគ្នាដើម្បី បង្កើនសមត្ថភាពច្នៃប្រឌិត និងកសាង ជំនាញច្នៃប្រឌិតខណៈពេលដែលយើងសិក្សា អំពីភូមិសាស្រ្តពិភពលោក។ ប្រការនេះ បានជំរុញទស្សនៈវប្បធម៌ថ្មី និងបានពង្រីក ចំណេះដឹងរបស់ពួកគេទាក់ទងនឹងភូមិសាស្រ្ត និង ពិភពលោកដែលយើងទាំងអស់គ្នា

រស់នៅ។ តាមរយៈការបង្កើតផែនទីពិភពលោករបស់យើង សិស្សានុសិស្សបានរៀនសូត្រអំពីដំណើរការទាំងមូល។ សិស្សានុសិស្សបានស្គាល់ប្រទេសថ្មីហើយអាចមើលឃើញអំពីទំហំខុសគ្នានៃប្រទេសទាំងនេះនៅពេលដែលពួកគេគូសប្រទេសនីមួយៗនៅលើជញ្ជាំង។ វាពិតជាគួរឱ្យរំភើបខ្លាំងណាស់ដែលបានឃើញសិស្សចាប់អារម្មណ៍ខ្លាំងលើពិភពលោក ហើយពួកគេទទួលបានបទពិសោធន៍ជាក់ស្តែង ដែលបង្កើតឡើងពីការរួមចំណែករបស់ពួកគេ ទាំងនេះបានឆ្លុះបញ្ចាំងអំពីទិដ្ឋភាពរួម។ សិស្សបានសួរសំណួរ និងបង្ហាញចំណាប់អារម្មណ៍លើគម្រោង ក៏ដូចជា ការកសាងទំនាក់ទំនងជាមួយមិត្តភ័ក្តិ និងគ្រូរបស់ពួកគេ។ យើងបានសហការគ្នាដើម្បីបង្កើតរូបភាពដ៏ធំនៃពិភពលោករបស់យើង។ យើងទន្ទឹងរង់ចាំទទួលថ្នាំលាបដើម្បីអាចបន្ថែមពណ៌ចូលទៅក្នុងពិភពលោកនៃការអប់រំរបស់ពួកគេ!

## ការបង្កើតឱកាសថ្មីតាមរយៈភាសាអង់គ្លេស ពីអ្នកស្ម័គ្រចិត្ត




**K15 PCV Raynold Chen**

កាលពីថ្ងៃច័ន្ទទី២៩ខែកក្កដា ខ្ញុំបានរៀបចំព្រឹត្តិការណ៍ ភាសាអង់គ្លេសដំបូងគេបង្អស់ក្នុងប្រវត្តិសាស្ត្រសាលានៃវិទ្យាល័យរបស់ខ្ញុំ។ វិទ្យាល័យ ហ៊ុនសែន កំពង់ចក គឺជាសាលាមានវ័យចំណាស់ជាងគេនៅក្នុងស្រុក ប៉ុន្តែមិនដែលមានព្រឹត្តិការណ៍ភាសាអង់គ្លេសអ្វីមួយឡើយគិតមកដល់ឆ្នាំនេះ។ គ្រូដៃគូរបស់ខ្ញុំម្នាក់ និងខ្ញុំបានជ្រើសរើសសិស្ស៤នាក់ពីថ្នាក់ទី ១០ របស់យើង ដើម្បីនិយាយភាសាអង់គ្លេសនៅមុខសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូនៅក្នុងសាលាទាំងមូល។ យើងក៏បានជ្រើសរើសសិស្ស ៤ នាក់ថែមទៀតពីថ្នាក់របស់ពួកគេដើម្បីបកប្រែមកជាភាសាខ្មែរ ក្នុងព្រឹត្តិការណ៍ភាសាអង់គ្លេសនេះ។សិស្សដែលនិយាយភាសាអង់គ្លេសទាំង៤ នាក់បានរៀបចំចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេដោយខ្លួនឯង ជាជាងគ្រូដៃគូរបស់ខ្ញុំ និងខ្ញុំរៀបចំចំណាប់អារម្មណ៍នោះឱ្យពួកគេ។ ប្រការនេះធ្វើឱ្យចំណាប់អារម្មណ៍កាន់តែមានលក្ខណៈផ្ទាល់ខ្លួន។ចំណាប់អារម្មណ៍លើកឡើងអំពីមូលហេតុដែលអ្នកគួររៀនភាសាអង់គ្លេសនិងអំពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ ពេញមួយខែ កក្កដា នេះ គ្រូដៃគូរបស់ខ្ញុំ និងខ្ញុំបានជួបជាមួយសិស្សទាំងបួននាក់នេះជារៀងរាល់សប្តាហ៍ ដើម្បីជួយពួកគេហាត់អាននៅចំពោះមុខទស្សនិកជនដ៏ច្រើន ក៏ដូចជាការបញ្ចេញសំឡេងរបស់ពួកគេ។ ព្រឹត្តិការណ៍នេះប្រមូលបានទស្សនិកជនសរុបជាង ៤០.០០០នាក់។ អភិបាលរងស្រុកខ្ញុំ រួមជាមួយមន្ត្រីក្រសួងអប់រំមួយចំនួនផ្សេងទៀតបានអញ្ជើញចូលរួមក្នុងពិធីនេះ។ វិទ្យាល័យផ្សេងទៀតនៅក្នុងតំបន់បានប្រាប់នាយកសាលាខ្ញុំថាព្រឹត្តិការណ៍នេះគឺអស្ចារ្យណាស់។ ពួកគេបានទទួលស្គាល់ព្រឹត្តិការណ៍របស់យើង ហើយបានប្រាប់នាយកសាលាខ្ញុំថា ពួកគេមានគម្រោងបង្កើតព្រឹត្តការណ៍ស្រដៀងគ្នានេះនាពេលអនាគត ដោយសារសហគមន៍បានទទួលស្វាគមន៍យ៉ាងខ្លាំង។ វាមិនមែនជា ព្រឹត្តិការណ៍ប្រកួតប្រជែងទេ។ វាគឺជាព្រឹត្តការណ៍ដែលបង្ហាញពីសក្តានុពលរបស់សិស្សតាមរយៈភាសាអង់គ្លេស។ សិស្សទាំង៤នាក់ បាននិយាយនៅចំពោះមុខសាលាទាំងមូលដោយមិនមានកំហុសអ្វីឡើយ។





# កម្មវិធីគម្រោងអភិវឌ្ឍន៍ខ្នាតតូច និងសមិទ្ធផល

ទស្សនភីស ខ័រចំពោះការអភិវឌ្ឍគឺសំដៅជួយមនុស្សក្នុងការអភិវឌ្ឍសមត្ថភាពដើម្បីប្រើប្រាស់ធនធាន និងជំនាញផ្ទាល់ខ្លួនរបស់ពួកគេដើម្បីដោះស្រាយតម្រូវការរបស់សហគមន៍ពួកគេ និងផ្តល់ភាពអង់អាចដល់ពួកគេតាមរយៈការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើម្បីកែលម្អជីវិតរបស់ពួកគេ ដោយមានការចូលរួម បរិយាបន្ន និងដឹកនាំដោយសហគមន៍។ ក្នុងឆ្នាំ ២០២៤ ភីស ខ័រ កម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣ ស្តីពីការរៀបចំតាក់តែងនិងគ្រប់គ្រងគម្រោង ជូនអ្នកស្ម័គ្រចិត្តភីស ខ័រ ចំនួន ៣២នាក់ គ្រូដៃគូចំនួន ៣២នាក់ មកពីសាលារៀន និងយុវជនស្ម័គ្រចិត្តចំនួន ៦០នាក់ មកពីកម្មវិធីអ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ។ គោលបំណងនៃកម្មវិធីនេះ គឺសំដៅបណ្តុះបណ្តាល និងកសាងសមត្ថភាពរបស់អ្នកចូលរួមទាំងអស់អំពីរបៀបកំណត់តម្រូវការពិតប្រាកដរបស់សហគមន៍ និងសរសេរសំណើគម្រោងដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ។



# ដំណើររឿងជោគជ័យនៃគម្រោងអភិវឌ្ឍន៍ខ្នាតតូច








## សួនដំណាំផ្ទះបៃតងសាលាផលិតបន្លែសរីរាង្គសម្រាប់សហគមន៍ដែលមានសុខភាពល្អ

វិទ្យាល័យមួយក្នុងខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា បានកំណត់តម្រូវការផ្ទះបៃតង និងប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាថាកម្មវិធីសួនដំណាំរបស់ខ្លួនអាចបន្តបានពេញមួយរដូវប្រាំង។ មុនពេលគម្រោងចាប់ផ្តើម វិទ្យាល័យនេះមានការលំបាកក្នុងធ្វើសួនដំណាំក្នុងរដូវប្រាំង ដោយសារកង្វះធនធាន និងប្រព័ន្ធផ្គត់ផ្គង់ទឹកដែលប្រកបដោយប្រសិទ្ធភាព។ សិស្សបានដងទឹកស្រះ ឬប្រើទុយោដើម្បីស្រោចដំណាំ ដែលជាហេតុធ្វើឱ្យទឹកស្រះរីងស្ងួត ហើយ ប្រឡាក់ឯកសណ្ឋានសាលារបស់សិស្ស។ ក្រោយពេលទទួលបានថវិកា បុគ្គលិកសាលា និងសិស្សានុសិស្សបានស្ម័គ្រចិត្តប្រើពេលទំនេររបស់ខ្លួនដើម្បីសាងសង់ផ្ទះបៃតង និងដំឡើងប្រព័ន្ធធារាសាស្ត្រ រួមទាំងម៉ាស៊ីនបូមទឹកមួយ និងធុងស្តុកទឹកមួយ ក៏ដូចជា ពង្រីកស្រះដែលជាប្រភពទឹកចម្បង។

ក្រោយពេលដែលផ្ទះបៃតងត្រូវបានរៀបចំហើយ សាលាបានផលិតជីកាកសំណល់ដោយខ្លួនឯង និងដាំដំណាំសរីរាង្គ។ ដោយមានការរួមបញ្ចូលគ្នានូវ ផ្ទះបៃតង រណ្តៅជី និងការពង្រីកស្រះទឹក សាលារៀនអាចចាប់ផ្តើមធ្វើសួនដំណាំសាលាប្រកបដោយនិរន្តរភាពយ៉ាងជោគជ័យ។ លទ្ធផលដែលទទួលបានពីគម្រោងជំនួយហិរញ្ញប្បទាននេះ គឺមិនត្រឹមតែជាការសាងសង់ផ្ទះបៃតងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱ្យសាលានូវឧបករណ៍ដើម្បី ទ្រទ្រង់គម្រោងនេះ រួមមានប្រព័ន្ធផ្គត់ផ្គង់ទឹកជាដើម។ គម្រោងនេះ បានបង្រៀនបុគ្គលិកសាលា និងសមាជិកសហគមន៍ឱ្យធ្វើការងារជាក្រុម និងជំរុញទឹកចិត្តសិស្សឱ្យចូលរួមចំណែកក្នុងសួនដំណាំរបស់ពួកគេ។

## គម្រោងអភិវឌ្ឍន៍បណ្ណាល័យ៖ ឥទ្ធិពលនៃបណ្ណាល័យដែលបានកែលម្អរួច

សាលាបឋមសិក្សាមួយបានកំណត់ភាពចាំបាច់កែលម្អបណ្ណាល័យដែលមានស្រាប់ឡើងវិញដើម្បីផ្តល់ឱ្យសិស្សានុសិស្ស គ្រូបង្រៀននិងសមាជិកសហគមន៍នូវលទ្ធភាពប្រើប្រាស់បណ្ណាល័យនិងធនធានឌីជីថលដោយឥតគិតថ្លៃ។មុនពេលគម្រោងជំនួយហិរញ្ញប្បទានបានចាប់ផ្តើម គ្រូបង្រៀនជាច្រើនមានបទពិសោធន៍ប្រើប្រាស់កុំព្យូទ័រតិចតួច។ នាយកសាលាមានចក្ខុវិស័យចង់កែប្រែសាលាឱ្យផ្តោតលើអក្ខរកម្មភាសាអង់គ្លេស និងឌីជីថល ប៉ុន្តែ អវត្តមានកុំព្យូទ័របានធ្វើឱ្យគោលដៅនេះមិនអាចសម្រេចបាន។ គម្រោងជំនួយហិរញ្ញប្បទាននេះ ត្រូវបានប្រើប្រាស់ដើម្បីជួសជុលបណ្ណាល័យ និងទិញផ្ទើសៀវភៅថ្មីៗ សៀវភៅ និងបច្ចេកវិទ្យាដទៃទៀត។ ទន្ទឹមនឹងនេះ គម្រោងជំនួយហិរញ្ញប្បទានក៏បានគាំទ្រការរៀបចំសិក្ខាសាលាកុំព្យូទ័រសម្រាប់គ្រូបង្រៀន និងសិស្សានុសិស្សឱ្យបានរៀនពីរបៀបប្រើប្រាស់បច្ចេកវិទ្យាថ្មីនេះ។

ក្រោយពេលបណ្ណាល័យត្រូវបានកែលម្អ គ្រូបង្រៀន ៥០% បានចូលរួមសិក្ខាសាលាស្តីអំពីកុំព្យូទ័រដែលរៀបចំដោយអ្នកស្ម័គ្រចិត្តភីស ខ័រ។ ចំណុចនេះបានធ្វើឱ្យគ្រូបង្រៀនមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់៖ លោកគ្រូ អ្នកគ្រូដែលកាលពីគ្រាដំបូងមានការលំបាកជាមួយមុខងារកុំព្យូទ័រជាមូលដ្ឋាន ឥឡូវនេះបានដំណើរការមុខងារទាំងនេះបានយ៉ាងងាយ ហើយគ្រូជាច្រើនចេះវាយអក្សរជាខេមរភាសាដោយប្រើក្តារចុចកុំព្យូទ័រ។ លើសពីនេះទៅទៀត បណ្ណាល័យគឺជាកន្លែងដ៏ពេញនិយមមួយសម្រាប់អ្នកប្រើប្រាស់ដទៃទៀត៖ សិស្សានុសិស្សថ្នាក់បឋមសិក្សាបានទៅស្វែងរកសៀវភៅថ្មីៗ ចំណែកឯសិស្សអនុវិទ្យាល័យ និងសិស្សវិទ្យាល័យប្រើទីកន្លែងនេះដើម្បីធ្វើកិច្ចការនិងអានសៀវភៅ ហើយសមាជិកសហគមន៍ប្រើកន្លែងនេះសម្រាប់កិច្ចប្រជុំ និងការពិភាក្សាគម្រោង។ ទន្ទឹមនឹងនេះ បណ្ណាល័យក៏ជាទីកន្លែងសម្រាប់ក្លឹបសិក្សាភាសាអង់គ្លេសមួយ ដែលជំរុញការរៀនភាសាបន្ថែមទៀតផងដែរ។ គំនិតផ្តួចផ្តើមជួសជុលកែលម្អបណ្ណាល័យនេះ មិនត្រឹមតែបានលើកកម្ពស់ការប្រើប្រាស់បណ្ណាល័យប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបណ្តុះឱ្យមានស្មារតីសហគមន៍ និងស្មារតីរៀនសូត្រកាន់តែរឹងមាំថែមទៀតផង។












## គម្រោងអក្ខរកម្មឌីជីថល

សាលាបឋមសិក្សាមួយនៅកម្ពុជា បានកំណត់ភាពចាំបាច់នៃការដាក់បញ្ចូលអក្ខរកម្មបែបឌីជីថលទៅក្នុងកម្មវិធីសិក្សារបស់ខ្លួន ដើម្បីកែលម្អការបង្រៀន បង្កើនការចូលរួមរបស់សិស្ស និងកែលម្អអក្ខរកម្មបែបឌីជីថល។ បុគ្គលិកសាលាដែលគាំទ្រដោយអ្នកស្ម័គ្រចិត្ត បានដាក់ស្នើនូវផែនការមួយដើម្បីពង្រឹងសមត្ថភាពដោយធ្វើ បច្ចុប្បន្នភាព បច្ចេកវិទ្យា និងពង្រឹងកម្មវិធីសិក្សារបស់សាលាដើម្បីដាក់បញ្ចូលការសិក្សាបែបឌីជីថលដោយលំហាត់អនុវត្ត។ គម្រោងជំនួយហិរញ្ញប្បទាននេះត្រូវបានប្រើដើម្បីទិញរ៉ោតទ័រ Wi-Fi ថ្មីមួយ ប្រដាប់បញ្ចាំងមួយ ទូរទស្សន៍ឆ្លាតវៃ និងកុំព្យូទ័រ ដើម្បីធ្វើបច្ចុប្បន្នភាពឧបករណ៍ឌីជីថលរបស់សាលា។

ក្រោយការរៀបចំរួចរាល់ លោកគ្រូ អ្នកគ្រូបានចូលរួមក្នុងសិក្ខាសាលាស្តីអំពីអក្ខរកម្មឌីជីថលមួយដែលដឹកនាំដោយគ្រូបង្រៀនផ្នែកអក្ខរកម្មបែបឌីជីថលថ្មី។ បន្ទាប់ពីវគ្គបំប៉នបានបញ្ចប់ លោកគ្រូ អ្នកគ្រូបានសម្របខ្លួនទៅនឹងវិធីសាស្រ្តបង្រៀនថ្មី និងបានដាក់បញ្ចូលនូវឧបករណ៍ឌីជីថល ទៅក្នុងការរៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃរបស់គាត់ប្រកបដោយជោគជ័យ។ ដើម្បីវាស់ស្ទង់អំពីវឌ្ឍនភាពរបស់សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូការវាយតម្លៃត្រូវបានធ្វើឡើងជាប្រចាំ។ គួរកត់សម្គាល់ថា ជាង ៨០% នៃសិស្សបានឆ្លងកាត់ការវាយតម្លៃអក្ខរកម្មឌីជីថល។ គម្រោងនេះមិនត្រឹមតែបានផ្សារភ្ជាប់គម្លាតនៅក្នុងអក្ខរកម្មបែបឌីជីថលតាមរយៈសកម្មភាពពង្រឹងសមត្ថភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបើកទ្វារសម្រាប់ឱកាសការងារនាពេលអនាគត និងផ្តល់ភាពអង់អាចដល់គ្រូនិងសិស្សជាមួយជំនាញដែលចាំបាច់ដើម្បីរីកចម្រើនក្នុងសង្គមមួយដែលកាន់តែមានលក្ខណៈឌីជីថល ថែមទៀតផង។





# ការបណ្តុះបណ្តាលបឋម

ការបណ្តុះបណ្តាលបឋម ត្រូវបានផ្តល់ជូនអ្នកស្ម័គ្រចិត្ត ភីស ខ័រ នីមួយៗនូវជំនាញសំខាន់ៗ ដើម្បីបំពេញការងារធ្វើសមាហរណកម្ម និងរស់នៅក្នុងសហគមន៍កម្ពុជាប្រកបដោយប្រសិទ្ធភាព។ នៅឆ្នាំ ២០២៤ ភីស ខ័រ បានរៀបចំការបណ្តុះបណ្តាលបឋមរយៈពេល ១០ សប្តាហ៍ នៅខេត្តតាកែវ សម្រាប់អ្នកស្ម័គ្រចិត្តចំនួន ៣២ នាក់។ ប្រធានបទសំខាន់ៗរួមមានជំនាញបង្រៀនភាសាអង់គ្លេស ភាសានិងវប្បធម៌ខ្មែរ ប្រវត្តិសាស្រ្តកម្ពុជា សុវត្ថិភាពនិងសន្តិសុខ និងសុខភាព។



មុនពេលបញ្ជូនអ្នកស្ម័គ្រចិត្តទៅធ្វើការតាមសាលារៀន ឬនៅមជ្ឈមណ្ឌលគរុកោសល្យទូទាំងប្រទេស អ្នកស្ម័គ្រចិត្តបានរៀនពីរបៀបបង្រៀននៅក្នុងសាលាកម្ពុជា និងវិធីសាស្រ្តធ្វើសមាហរណកម្មទៅក្នុងវប្បធម៌កម្ពុជា។ ក្នុងអំឡុងពេលបណ្តុះបណ្តាលបឋម អ្នកស្ម័គ្រចិត្តភីស ខ័រ បានរៀនភាសាខ្មែរពីអ្នកសម្របសម្រួលភាសា និងវប្បធម៌ និងរស់នៅក្នុងសហគមន៍ជាមួយគ្រួសារខ្មែរ ដែលផ្តល់ឱកាសឱ្យពួកគេហាត់រៀនប្រើប្រាស់ភាសាខ្មែរនៅក្រៅថ្នាក់រៀន និងបានជួយពួកគេឱ្យសម្របខ្លួនទៅនឹងវប្បធម៌ខ្មែរ។



អ្នកស្ម័គ្រចិត្តភីស ខ័រ រៀនភាសាខ្មែរ

គ្រូឧទ្ទេសបច្ចេកទេស គឺជាគ្រូដែលមានបទពិសោធន៍បង្រៀនផ្នែកភាសាអង់គ្លេសនៅកម្ពុជា។ ពួកគេបានផ្តល់ឱ្យអ្នកស្ម័គ្រចិត្តនូវជំនាញបង្រៀនដែលពួកគេត្រូវការ ដើម្បីទទួលបានជោគជ័យនៅក្នុងសាលាកម្ពុជា។ អ្នកស្ម័គ្រចិត្តបានបញ្ចប់ការបង្រៀនសាកល្បងរយៈពេលពីរសប្តាហ៍និងការបង្រៀនក្នុងសហគមន៍ចំនួន៣សប្តាហ៍ដើម្បីផ្តល់ជូនពួកគេនូវបទពិសោធន៍ជាក់ស្តែងមុនពេលទៅបង្រៀននៅតាមសាលាគោលដៅរបស់ពួកគេ។










ការបង្រៀនសាកល្បងនិងបង្រៀនក្នុងសហគមន៍ បានជួយអ្នកស្ម័គ្រចិត្តឱ្យទទួលបានបទពិសោធន៍បង្រៀន



អ្នកស្ម័គ្រចិត្តភីស ខ័រ ក៏បានរៀនបំណិនជីវិតជាមូលដ្ឋានមួយចំនួនផងដែរ ដើម្បីជួយពួកគេឱ្យសម្របខ្លួនទៅនឹងការរស់នៅជាក់ស្តែងនៅក្នុងសហគមន៍ជនបទកម្ពុជា។ ពួកគេបានរៀនជំនាញជួសជុលកង់ជាមូលដ្ឋាន ការបោកគក់ដោយដៃ និងសុជីវធម៌ក្នុងការទទួលទានអាហារជាមួយគ្រួសារម្ចាស់ផ្ទះរបស់ពួកគេ។





រៀនបំណិនជីវិតជាមូលដ្ឋាន





អ្នកស្ម័គ្រចិត្តក៏បានទទួលការបណ្តុះបណ្តាលយ៉ាងច្រើនផងដែរលើប្រធានបទទាក់ទងនឹងសុខភាព និងសន្តិសុខ និងសុវត្ថិភាព ដើម្បីធានាថាពួកគេមានសុខភាពល្អនិងមានសុវត្ថិភាពក្នុងអំឡុងពេលបំពេញការងារ។









ការបណ្តុះបណ្តាលផ្នែកសុខភាព និង សុវត្ថិភាពនិងសន្តិសុខ

# ការបណ្តុះបណ្តាលនានារបស់ ទីភ្នាក់ងារភីស ខ័រ

## សិក្ខាសាលាស្តីពី កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ជាមួយគណៈគ្រប់គ្រងសាលា និងគ្រូដៃគូ



សិក្ខាសាលាស្តីពី កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ជាមួយគណៈគ្រប់គ្រងសាលា និងគ្រូដៃគូ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយដែលត្រូវបានបង្កើតឡើងដើម្បីបង្កើនកិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ និងគ្រូដៃគូក្នុងស្រុករបស់ពួកគេ។ សិក្ខាសាលានេះបំពេញមុខងារជាវេទិកា មួយដើម្បីជំរុញការយោគយល់គ្នាទៅវិញទៅមក ចែករំលែកបទពិសោធន៍ និងអភិវឌ្ឍយុទ្ធសាស្រ្តដែលស្របតាមគោលដៅរបស់ទីភ្នាក់ងារភីស ខ័រ ទៅនឹងតម្រូវការរបស់សហគមន៍ដែលពួកគេបំពេញការងារ។

នៅក្នុងការអភិវឌ្ឍវិស័យអប់រំ កិច្ចសហការរវាងនាយកសាលាក្នុងមូលដ្ឋាន គ្រូដៃគូ និងអ្នកស្ម័គ្រចិត្ត ភីស ខ័រ គឺជាចំណុចសំខាន់សម្រាប់ជំរុញការកើនឡើងប្រកបដោយនិរន្តរភាព និងការលើកកម្ពស់គុណភាពនៃការអប់រំភាសាអង់គ្លេស។ របាយការណ៍នេះគូសបង្ហាញពីសិក្ខាសាលានាពេលថ្មីៗនេះដែលបានប្រមូលផ្តុំនាយកសាលា និងគ្រូដៃគូមកពីតំបន់ផ្សេងៗចំនួន១៣ខេត្តនៃប្រទេសកម្ពុជា៖ បន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង ព្រះវិហារ ត្បូងឃ្មុំ កំពង់ចាម ព្រៃវែង ស្ទឹងត្រែង កំពត តាកែវ និង ក្រចេះ ដែលបង្ហាញពីភាពជាដៃគូប្រកបដោយជោគជ័យ ការអនុវត្តក្នុងលក្ខណៈនវានុវត្តន៍ និងគោលដៅអនាគត។

## ទិដ្ឋភាពទូទៅនៃសិក្ខាសាលា

សិក្ខាសាលាប្រចាំឆ្នាំបានប្រព្រឹត្តទៅនៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥-១៦ ខែតុលា ឆ្នាំ២០២៤ ដោយបានទាក់ទាញអ្នកចូលរួមជាង ១២៤នាក់ រួមមាននាយកសាលា គ្រូដៃគូ និងអ្នកស្ម័គ្រចិត្ត ភីស ខ័រ។ គោលដៅចម្បងនៃសិក្ខាសាលាគឺសំដៅពង្រឹងកិច្ចសហការរវាងអាជ្ញាធរអប់រំក្នុងមូលដ្ឋាន និងអ្នកស្ម័គ្រចិត្ត ភីស ខ័រ តាមរយៈការចែករំលែកបទពិសោធន៍ បញ្ហាប្រឈមដែលជួបប្រទះក្នុងវិស័យនេះ និងយុទ្ធសាស្រ្តសម្រាប់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព។










## សិក្ខាសាលា និងការពិភាក្សាជាក្រុម

សមាសធាតុសំខាន់មួយនៃសិក្ខាសាលាគឺសិក្ខាសាលាជាបន្តបន្ទាប់ដែលផ្តោតលើការលើកកម្ពស់ជំនាញទំនាក់ទំនង អភិក្រម ភីស ខ័រ ចំពោះការអភិវឌ្ឍ តួនាទី និងការទទួលខុសត្រូវ ការរំពឹងការងារ ការបង្រៀនរួមគ្នា វិធីសាស្ត្របង្រៀនភាសាអង់គ្លេស ការប្រើប្រាស់បញ្ញាសិប្បនិម្មិត/kahoot ក្នុងការបង្រៀនភាសាអង់គ្លេស គំនិតអភិវឌ្ឍសម្រាប់គម្រោងក្រៅពីការបង្រៀនផែនការសមាហរណកម្មសហគមន៍ សុវត្ថិភាព និងសន្តិសុខអ្នកស្ម័គ្រចិត្ត និងសមត្ថភាពវប្បធម៌។ ខាងក្រោមនេះជាឧទាហរណ៍នៃសិក្ខាសាលាមួយដែលមានឈ្មោះថា "ការប្រាស្រ័យទាក់ទងបែបអន្តរវប្បធម៌" ផ្តល់ជូនសិក្ខាកាមនូវមធ្យោបាយសម្រាប់ជំនះនូវឧបសគ្គភាសា ក៏ដូចជាភាពខុសគ្នានៃវប្បធម៌ប្រកបដោយប្រសិទ្ធភាព។








## ការចែករំលែកបទពិសោធន៍ជោគជ័យនៃកិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ជាមួយគណៈគ្រប់គ្រងសាលា

នាយកសាលាជាច្រើនបានចែករំលែកដំណើររឿងជោគជ័យដែលគួសបញ្ជាក់ពីកិច្ចសហការរបស់ពួកគេជាមួយអ្នកស្ម័គ្រចិត្តភីស ខ័រ មុនៗ។ ខាងក្រោមនេះគឺជាការលើកឡើងរបស់នាយកសាលាពីររូប៖



**នាយកសាលាមកពីវិទ្យាល័យ បាក់ចិញ្ចៀនក្នុងខេត្តពោធិ៍សាត់ លោក ស៊ុំ ផារិទ្ធ ៖**

បានចែករំលែកពីរបៀបដែលអ្នកស្ម័គ្រចិត្តភីស ខ័រ Joleen Xiong បានជួយអនុវត្តគម្រោងសួនដំណាំធម្មជាតិសាលា ក្រៅពីការបង្រៀនភាសាអង់គ្លេសដល់សិស្ស។



**នាយកសាលាមកពីសាលាបឋមសិក្សាគីរីសុវណ្ណវង្សនៅខេត្តកំពង់ឆ្នាំង លោក យិន ចាន់ឌី៖**

ក្រៅពីបង្រៀនភាសាអង់គ្លេសដល់សិស្សថ្នាក់ទី ៤-៦ អ្នកស្ម័គ្រចិត្ត ភីស ខ័រ Jake Upton របស់យើងបានសាងសង់បន្ទប់កុំព្យូទ័រមួយក្នុងបណ្ណាល័យសាលា។

ដំណើររឿងទាំងនេះមិនត្រឹមតែបានជំរុញលើកទឹកចិត្តអ្នកចូលរួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញពីឥទ្ធិពលជាក់ស្តែងនៃកិច្ចខិតខំរួមគ្នាថែមទៀតផង។

## ឱកាសបង្កើតទំនាក់ទំនង



សិក្ខាសាលានេះក៏បានផ្តល់ឱកាសច្រើនសម្រាប់ការបង្កើតទំនាក់ទំនងផងដែរ។ក្នុងពេលសម្រាកសិក្ខាកាមបានចូលរួមការពិភាក្សាក្រៅផ្លូវការ ការណ៍នេះបានអនុញ្ញាតឱ្យពួកគេបង្កើតទំនាក់ទំនងថ្មី និងចែករំលែកបទពិសោធន៍ទៅវិញទៅមក។ សិក្ខាកាមជាច្រើនបានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការបង្កើតក្រុមជដែកគ្នា ដើម្បីបង្កើតទំនាក់ទំនងរវាងនាយកសាលាដែលមានបទពិសោធន៍ និងនាយកសាលាថ្មីដែលទើបតែចាប់ផ្តើមដំណើររបស់ពួកគេជាមួយអ្នកស្ម័គ្រចិត្ត ភីស ខ័រ ។

សិក្ខាសាលាបានបញ្ចប់ដោយជោគជ័យ និងការតាំងចិត្តខ្ពស់ពីសិក្ខាកាមទាំងអស់ក្នុងការបន្តជំរុញ កិច្ចសហការរវាងនាយកសាលា គ្រូដៃគូ និងអ្នកស្ម័គ្រចិត្ត ភីស ខ័រ ។

សិក្ខាសាលាស្តីពី កិច្ចសហការរវាងអ្នកស្ម័គ្រចិត្ត ភីសខ័រ ជាមួយគណៈគ្រប់គ្រងសាលា និងគ្រូដៃគូ គឺជាបទពិសោធន៍មិនអាចកាត់ថ្លៃបានមួយសម្រាប់អ្នកចូលរួមទាំងអស់។ការផ្តោតសំខាន់លើកិច្ចសហការការប្រាស្រ័យទាក់ទងនិងសមាហរណកម្មសហគមន៍ សិក្ខាសាលានេះបានពង្រឹងបេសកកម្មរបស់អ្នកស្ម័គ្រចិត្ត ភីស ខ័រ៖ បង្កើតការផ្លាស់ប្តូរជាប់លាប់ តាមរយៈភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន។ ស្របពេលដែលយើងបោះជំហានទៅមុខក្នុងឆ្នាំបន្ទាប់ យើងមានសុទិដ្ឋិនិយមចំពោះទំនាក់ទំនងដ៏រឹងមាំដែលបានបង្កើតឡើងក្នុងសិក្ខាសាលានេះ។



## ពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរ ដែលនឹងរស់នៅជាមួយអ្នកស្ម័គ្រចិត្តក្រុមទី ១៦

នៅកម្ពុជា ពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរប្រចាំឆ្នាំគឺជាមូលដ្ឋានគ្រឹះមួយសម្រាប់ជំរុញការផ្សារភ្ជាប់ទំនាក់ទំនង រវាងអ្នកស្ម័គ្រចិត្ត និងគ្រួសារខ្មែររបស់ពួកគេ។ ក្នុងឆ្នាំនេះ ពិធីសំណេះសំណាលបានប្រារព្ធធ្វើឡើងនៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ ដែលមានសមាជិកគ្រួសារម្ចាស់ផ្ទះចំនួន ៧០ នាក់មកពី ១៣ ខេត្តនៃប្រទេសកម្ពុជា ខេត្តទាំងនោះរួមមាន៖ បន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង ព្រះវិហារ ត្បូងឃ្មុំ កំពង់ចាម ព្រៃវែង ស្ទឹងត្រែង ក្រចេះ តាកែវ និងកំពត បានជួបជុំគ្នាដើម្បីស្វែងយល់អំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ក៏ដូចជាបង្កើតបរិយាកាសបរិយាបន្ន មួយសម្រាប់អ្នកស្ម័គ្រចិត្តរបស់ពួកគេ ។



គ្រួសារម្ចាស់ផ្ទះមកពីខេត្តបន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង និងព្រះវិហារ

## សុន្ទរកថាស្វាគមន៍

នៅពេលដែលក្រុមគ្រួសារម្ចាស់ផ្ទះបានមកដល់ ពួកគេត្រូវបានស្វាគមន៍ដោយបុគ្គលិកផ្នែកកម្មវិធី ព្រមទាំង នាយកផ្នែកកម្មវិធី និងបណ្តុះបណ្តាលរបស់យើង គឺលោក ម៉ៃឃើល យៀល។ គាត់បានគូសបញ្ជាក់ថាគ្រួសារម្ចាស់ផ្ទះដើរតួនាទីយ៉ាងសំខាន់សម្រាប់ភាពជោគជ័យរបស់អ្នកស្ម័គ្រចិត្តនីមួយៗតាមរយៈការជួយគាំទ្រពួកគាត់បញ្ច្រាបខ្លួនទៅក្នុងសហគមន៍ និងការបង្រៀនភាសា។ គាត់បានបញ្ជាក់ និងសាទរអ្នកស្ម័គ្រចិត្តដែលមានប្រវត្តិ និងការគិតផ្សេងៗគ្នា ស្របពេលជាមួយនេះដែរ គាត់បានសាទរចំពោះម្ចាស់ផ្ទះដែលបានស្វាគមន៍អ្នកស្ម័គ្រចិត្តមករស់នៅក្នុងផ្ទះ និងសហគមន៍របស់ពួកគាត់។គាត់ដឹងថាការរស់នៅជាមួយអ្នកស្ម័គ្រចិត្តមិនមែនជាការងាយស្រួលទេគឺទាមទារឱ្យមានការតាំងចិត្ត និងការអត់ធ្មត់ច្រើន សម្រាប់អ្នកស្ម័គ្រចិត្ត ក៏ដូចជាគ្រួសារម្ចាស់ផ្ទះ ស្របពេលជាមួយគ្នានេះដែរ បុគ្គលិកផ្នែកកម្មវិធីរបស់ទីភ្នាក់ងារ ភីស ខរ តែងតែត្រៀមខ្លួន ជាស្រេចដើម្បីជួយគាំទ្រផ្នែកភាសា ឧបសគ្គវប្បធម៌ និងការកសាងទំនាក់ទំនង។



លោក ម៉ៃឃើល យៀល នាយកកម្មវិធីនិងការបណ្តុះបណ្តាល កំពុងស្វាគមន៍គ្រួសារម្ចាស់ផ្ទះខ្មែរ

## ការយល់ដឹងពីភាពខុសគ្នានៃវប្បធម៌

បន្ទាប់ពីពិធីស្វាគមន៍ សិក្ខាសាលាស្ដីពីការយល់ដឹងអំពីវប្បធម៌ត្រូវបានធ្វើឡើងដោយប្រធានគ្រប់គ្រងកម្មវិធីរបស់យើង។ ពួកគេបានគូសបញ្ជាក់ពីភាពខុសគ្នានៃវប្បធម៌ទូទៅដែលអាចកើតឡើងក្នុងអំឡុងពេលដែលអ្នកស្ម័គ្រចិត្តរស់នៅជាមួយ។ ពួកគេបានពន្យល់ថា "ការយល់ដឹងអំពីលក្ខណៈខុសគ្នាទាំងនេះអាចជួយទប់ស្កាត់ការយល់ច្រឡំដែលអាចកើតមាន"។ គ្រួសារខ្មែរបានចូលរួមក្នុងសកម្មភាពអន្តរកម្មដែលបង្ហាញក្នុងសេណារីយ៉ូខុសៗគ្នាដែលពួកគេអាចជួបប្រទះជាមួយអ្នកស្ម័គ្រចិត្តរបស់ពួកគេ។


លោក សែន សង្ឃឹម ប្រធានគ្រប់គ្រងកម្មវិធី ដឹកនាំសិក្ខាសាលា


លោកស្រី អ៊ុំ វ៉ណាថារ័ត្ន ប្រធានគ្រប់គ្រងកម្មវិធី ដឹកនាំសិក្ខាសាលា

## ការអនុវត្តសុវត្ថិភាពនិងសន្តិសុខ

លើសពីនេះ យើងរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីសុវត្ថិភាពនិងសន្តិសុខដែលដឹកនាំដោយលោក គឹម រស្មី ជាប្រធានផ្នែកសុវត្ថិភាពនិងសន្តិសុខ ជូនដល់គ្រួសារម្ចាស់ផ្ទះខ្មែររបស់យើង ឆ្លៀតក្នុងឱកាសនោះយើងបានផ្ដល់នូវឧបករណ៍សុវត្ថិភាពមួយចំនួនសម្រាប់ប្រើប្រាស់នៅផ្ទះប្រកបដោយសុវត្ថិភាព។


លោក គឹម រស្មី ប្រធានផ្នែកសុវត្ថិភាពនិងសន្តិសុខ ដឹកនាំវគ្គសិក្ខាសាលាស្ដីពីសុវត្ថិភាពនិងសន្តិសុខ

## បទពិសោធន៍ជាក់ស្ដែងសម្រាប់ការទទួលធ្វើជាម្ចាស់ផ្ទះ

កម្មវិធីបន្ទាប់នៅក្នុងរបៀបវារៈ គឺការចែករំលែកបទពិសោធន៍ជាក់ស្ដែងដែលដឹកនាំដោយសមាជិកគ្រួសារម្ចាស់ផ្ទះដែលមានបទពិសោធន៍ក្នុងការរស់នៅជាមួយអ្នកស្ម័គ្រចិត្ត។ គ្រួសារម្ចាស់ផ្ទះ បានចែករំលែកការយល់ដឹងអំពីរបៀបបង្កើតបរិយាកាសផ្ទះដែលមានភាពកក់ក្ដៅ ការរៀបចំកន្លែងដែលមានផាសុខភាពសម្រាប់អ្នកស្ម័គ្រចិត្ត និងនាំពួកគេចូលក្នុងសកម្មភាពគ្រួសារជាដើម។ ។



**ម្ដាយខ្មែរម្នាក់ដែលមានបទពិសោធន៍រស់នៅជាមួយអ្នកស្ម័គ្រចិត្ត បានណែនាំថា**

" ចូរធ្វើឱ្យពួកគេមានអារម្មណ៍ដូចជាសមាជិកមួយរូបនៃគ្រួសាររបស់អ្នក "



**គ្រួសារម្ចាស់ផ្ទះចែករំលែកបទពិសោធន៍របស់ពួកគេ**

" អញ្ជើញពួកគេមកញ៉ាំអាហារពេលល្ងាច និងនាំពួកគេទៅចូលរួមក្នុងពិធីបុណ្យប្រពៃណីមួយចំនួន។ "

# យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព គឺជាប្រធានបទសំខាន់មួយទៀតដែលត្រូវបានពិភាក្សាក្នុងពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរ។ គ្រួសារម្ចាស់ផ្ទះបានសិក្សាអំពីរបៀបប្រាស្រ័យទាក់ទងផ្សេងៗគ្នា និងរបៀបជំនះឧបសគ្គភាសា។ នៅក្នុងការពិភាក្សាជាក្រុមមួយដែលមានអ្នកស្ម័គ្រចិត្តបច្ចុប្បន្នគឺ កញ្ញា Sarah Mcfadden និង លោក Caleb Glon បានរៀបរាប់អំពីបទពិសោធន៍ជាក់ស្តែងរបស់ពួកគេក្នុងការរស់នៅជាមួយគ្រួសារខ្មែរដោយគូសបញ្ជាក់ថា ការសន្ទនាបើកចំហមានសារៈសំខាន់សម្រាប់ការកសាងទំនុកចិត្ត។ អ្នកស្ម័គ្រចិត្តបានចែករំលែកថាអ្នកស្ម័គ្រចិត្តគឺមកពីមជ្ឈដ្ឋានផ្សេងៗគ្នា ទោះបីជាពួកគេជាជនជាតិអាមេរិកកាំងដូចគ្នាក្តី។ នៅសហរដ្ឋអាមេរិក គ្រួសារផ្សេងគ្នា មានវប្បធម៌ខុសៗគ្នា ហើយពួកគេបានលើកឧទាហរណ៍ខ្លះៗអំពីភាពខុសគ្នានៃការប្រើដៃម្ខាងរបស់ពួកគេដើម្បីជូនអំណោយទៅកាន់នរណាម្នាក់នៅអាមេរិក គឺវាមិនអីទេ ប៉ុន្តែសម្រាប់នៅកម្ពុជាវិញ គឺវាមិនសមរម្យទេ។



កញ្ញា Sarah Mcfadden និង លោក Caleb Glon ចែករំលែកបទពិសោធន៍របស់ពួកគេ

ពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរ បានបញ្ចប់ជាមួយនឹងឱកាសបង្កើតទំនាក់ទំនង ដែលនៅក្នុងនោះ គ្រួសារខ្មែរអាចភ្ជាប់ទំនាក់ទំនងគ្នា និងចែករំលែកព័ត៌មានសម្រាប់ទំនាក់ទំនង។ អ្នកចូលរួមជាច្រើនបានសម្តែងការសាទរចំពោះការបង្កើតមិត្តភាពមិនត្រឹមតែជាមួយអ្នកស្ម័គ្រចិត្តរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងចំណោមម្ចាស់ផ្ទះដូចគ្នាទៀតផង។ នៅពេលដែលក្រុមគ្រួសារខ្មែរបានចាកចេញពីពិធីសំណេះសំណាលនេះ ពួកគេបាននាំយកនូវចំណេះដឹង ព្រមទាំងអារម្មណ៍នៃស្មារតីសហគមន៍ដែលនឹងលើកស្ទួយបទពិសោធន៍នៃការធ្វើជាម្ចាស់ផ្ទះរបស់ពួកគេពេញមួយឆ្នាំ។

របាយការណ៍ប្រចាំឆ្នាំនេះ គូសបញ្ជាក់ថាពិធីសំណេះសំណាលជាមួយគ្រួសារខ្មែរមានសារៈសំខាន់ក្រៃលែងក្នុងការត្រៀមលក្ខណៈគ្រួសារខ្មែរដើម្បីការផ្លាស់ប្តូរអន្តរវប្បធម៌ប្រកបដោយជោគជ័យ ដោយធានាថាទាំង ម្ចាស់ផ្ទះ ទាំងអ្នកស្ម័គ្រចិត្តទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍ដ៏សម្បូណ៌បែបនេះ។



Peace Corps
CAMBODIA





















































# ការឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៅប្រទេសកម្ពុជា

ជាសុខភាព ភាពរឹងមាំ សេចក្តីស្រឡាញ់ ភាពវិជ្ជមាន ស្នាមញញឹម សហគមន៍ ការស្ញប់ស្ញែង ថាមពល អនុស្សាវរីយ៍ ភាពអត់ធ្មត់ គ្រួសារ ផ្ទះ...









**ទីស្នាក់ការ ពីស ខ័រ កម្ពុជា**

ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦

រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ២៨៥៣

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២២២ ៩០១

ទូរសារលេខ៖ (៨៥៥) ២៣ ២២២ ៩០៣

អ៊ីម៉ែល៖ KH-WebInfo@peacecorps.gov

**Follow us:**